# ជំនាញថ្មី សំរាប់ ជីវិតថ្មី

## សមាគមសិប្បកម្ម កម្ពុជា

សំរាប់ជនពិការដោយគ្រាប់មីន និង ជនប៉ូលីយ៉ូ

ផលិតដោយ ជនពិការដោយ **គ្រាប់មីន** និង **ប៉ូលីយ៉ូ** ក្នុង ព្រះរាជាណាចក្រកម្ពុជា

កម្មវិធីជួយទំនុកបំរុងខ្លួនឯង

សូត្រប្រពៃណីខ្មែរ
ហត្ថកម្មធ្វើដោយដៃ
វត្ថុអនុស្សាវរីយ៍
ប័ណ្ណជូនពរ
អំណោយជាកាដូ

សមាគមយើង

ខ្ញុំជាសមាគមក្នុងស្រុកជួយជនពិការគ្រោះថ្នាក់ដោយគ្រាប់មីន និង ជម្ងឺ ប៉ូលីយ៉ូ ឱ្យរៀនកាត់ដេរដោយគ្មានយកកំរៃក្នុងការសិក្សា ឡើយហើយសមាគម យើងពុំ មានជំនួយពីក្រៅប្រទេសធ្វើសកម្មភាពបំរើជូនជនពិការ ដោយពឹងពាក់អាស្រ័យ ដោយ ខ្លួនឯង ហើយក្រុមយើងខ្ញុំធ្វើការងារដោះស្រាយជីវភាពប្រចាំថ្ងៃ។

**Email Address:**
**wthanchashop@online.com.kh**

**<u>ប្រវត្តិសាវតារ:</u>**

បច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជាមានជនពិការរាប់ពាន់នាក់ ព្យាយាមខំប្រឹង បន្តការរស់នៅក្នុងប្រទេសដែលមានការលំបាកដោះស្រាយអោយ បានសមនឹង ចំនួន ដ៏ច្រើន លើសលប់នេះ ។ នៅក្នុងប្រទេសនេះដែរ ជន ពិការ ជាច្រើននាក់ប្រឈមមុខការលំបាកជាច្រើនជំពូក។ ក្នុងចំណោម ឧបសគ្គដោះស្រាយមិនចេញជាច្រើន មានឧបសគ្គមួយ ដែលជនពិការប្រឈមមុខ គឺ ការជួយឧបត្ថម្ភខ្លួនឯង និង គ្រួសាររបស់គេក្នុងពេល ពុះពាររាល់ជំនះ នៃ អសមត្ថភាពខ្លួនគេម្នាក់ៗ។ ដោយសារមានសង្គ្រាម ស៊ីវិលដ៏យូរអង្វែង នៅក្នុងប្រទេស កម្ពុជា គេប៉ាន់ប្រមាណជនពិការ ជាង ៤០.០០០ នាក់មាន ស្រី មានប្រុស និង កុមារ ដែលជាជន ពិការរង គ្រោះ រួចជីវិតផុតពីគ្រាប់មីន ។ ក្នុងនោះដែរដោយសារតែកង្វះខាត នៃ ការយកចិតទុកដាក់ ផ្នែកខាងវិជ្ជាពេទ្យ និង ការចាក់ថ្នាំបង្ការរោគចន្លោះពីឆ្នាំ ១៩៧៥-១៩៩០ ប្រជាជនកម្ពុជាជាច្រើននាក់ ទទួលរងគ្រោះដោយ ជម្ងឺ ស្វិតដៃ និង ជើង(ប៉ូលីយ៉ូ)។ មានអង្គការ ក្រៅរដ្ឋាភិបាលទាំងក្នុងស្រុក និង អន្តរជាតិព្រមទាំងក្រសួង ចំណុះរាជរដ្ឋាភិបាលជាច្រើនដំណើរការងារ នេះ ជូនជន ពិការ ។ ក្នុងចំណោមស្ថាបន័រដ្ឋអង្គការក្រៅរដ្ឋាភិបាលជាតិ និង អន្តរជាតិទាំងនោះមាន សមាគម សិប្បកម្មកម្ពុជា សំរាប់ជនពិការ ដោយសារគ្រាប់មីន និង ប៉ូលីយ៉ូ (CHA) មួយដែរជាគំរូធ្វើកិច្ចការនេះ។




សូមថ្លែងអំណរគុណ ដ៏ជ្រាលជ្រៅទុកជាមុនចំពោះការជាវ និងកុម្ម៉ង់ ផលិតផលដែលធ្វើដោយស្នាដៃបងប្អូនពិការ ។ អស់លោក លោក ស្រី មិនត្រឹមតែបានទទួល ផលិតផលដែលមានគុណភាព ខ្ពស់ប៉ុណ្ណោះទេ ថែមទាំងបាន គាំទ្រកម្មវិធីរបស់យើង ដែលផ្តល់ ជូនការងារ និង ឱកាសរកប្រាក់ ចំណូល ដល់បងប្អូនពិការយើង។

សូមអញ្ជើញមកមើលផលិតផល ស្នាដៃសិប្បករ សិប្បការិនីរបស់យើង ផលិត១ អស់ជាច្រើនខែកន្លងមកហើយ បងប្អូនពិការជ្រកតាមសំយាមផ្ទះ គ្មានសេចក្តីសង្ឃឹម គ្មានការអប់រំ គ្មានផ្ទះសម្បែង គ្មានជំនាញ គ្មានមិត្តភ័ក្ត និង គ្មានលុយកាក់ ប៉ុន្តែឥឡូវនេះ បងប្អូនពិការយើងបានចាប់ផ្តើមផលិត សិប្បផល សំរាប់ផ្តល់ទីផ្សារនានាក្នុងពិភពលោក ។

សូមអរគុណទុកជាមុន សំរាប់ការជួយជ្រោមជ្រែងកម្មវិធីយើងខ្ញុំ ដោយធ្វើការកុម្ម៉ង់ និងជាវផលិតផលដែលធ្វើដោយស្នាដៃបងប្អូន ជនពិការនៅសមាមរបស់យើងខ្ញុំ ( CHA ) ។

<u>សកម្មភាពលើកដំបូង</u>: សមាគមសិប្បកម្មកម្ពុជា ថ្មីៗនេះបានបើករោងសិប្បកម្មកាត់ដេរ និង តម្បាញ ដែលជាកន្លែងសិក្ខាកាមរៀនចប់វគ្គនៅ សាលាបណ្តុះបណ្តាលមុខវិជ្ជាជីវៈ អាចហ្វឹកហាត់ជំនាញរបស់គេ និងរៀនបន្ថែមនូវដំណើរការរកស៊ីជំនួញខ្នាតតូច។ ហាងបើកបំរើជាសាធារណៈនូវ ផលិតផលច្នៃប្រឌិតជាច្រើនដែលជាស្នាដៃរបស់ សិប្បករ សិប្បការិនី រងគ្រោះដោយ សារគ្រាប់មីន និងជម្ងឺប៉ូលីយ៉ូ ។



កិច្ចការនេះធ្វើឱ្យបងប្អូនពិការយើងអាចយកបទពិសោធន៍ នូវជំនឿទុកចិត្ត និង សេចក្តីពេញចិត្តដែលដុះចេញពី អ្នកចូលរួមសកម្មភាព ដ៏ថ្លៃថ្នូរនៅ ក្នុង សហគ្រិនដែលទទួលបានជោគជ័យ។ **រោងសិប្បកម្ម ផលិតកម្ម**: សមាគម សិប្បកម្មកម្ពុជា ត្រូវបានបង្កើតឡើង ដែលាមានសមាជិកយកមកពី សិក្ខា កាម រៀនចប់វគ្គពីសាលាបណ្តុះបណ្តាលមុខវិជ្ជជីវៈ សំរាប់ជនពិការដោ យ សារគ្រាប់មីន និង ប៉ូលីយ្យូ។ អ្នកចូលរួម សកម្មភាព ចំណាយពេលវេលា ៦ ទៅ ១២ ខែទៀត ដើម្បីបង្កើនជំនាញកាត់ដេរតម្បាញ និង ច្បាមយកបទ ពិសោធន៍គ្រប់គ្រង់បន្ថែមក្នុងការចាត់ចែងជំនាញ ខ្នាតតូច ។




សមាគម សិប្បកម្ម កម្ពុជា ( CHA ) មានសិប្បកម្ម ២ កន្លែង (មួយ កន្លែង នៅក្នុងរាជធានីភ្នំពេញ ដែលមានទីតាំងនៅ ផ្ទះជួលលេខ ១ ផ្លូវ ៣៥០ សង្កាត់ បឹងកេងកង៣ ខ័ណ្ឌ ចំការមន និង ១ កន្លែងទៀតនៅខេត្តសៀមរាប) ។ អស់លោក លោកស្រី អាចជួយឧបត្ថម្ភ ការប្រឹងប្រែងរបស់យើងខ្ញុំ ដោយ ធ្វើការជាវ និង កុម្ម៉ង់ ផលិតផលដែលធ្វើ ដោយស្នាដៃបងប្អូនពិការ ដោយ គ្រាប់មីន និង ជម្ងឺប៉ូលីយ្យូ ដែលគេទទួលស្គាល់ថា ផលិតផលទាំងនេះ គុណ ភាពល្អ ខ្ពស់បំផុត ។

**<u>សមាគម សិប្បកម្ម កម្ពុជា ( CHA ) នៅខេត្តសៀមរាបៈ</u>**

រោងសិប្បកម្មកាត់ដេរ និង តម្បាញ ស្ថិតនៅ ភូមិ ព្រះដាក់ ឃុំ ព្រះដាក់ ស្រុក បន្ទាយស្រី ផ្លូវទៅកាន់ ប្រាសាទបន្ទាយស្រី និង ភ្នំគូលេន ខេត្ត សៀមរាប។ សិក្ខាកាមរៀនចប់វគ្គផ្នែកកាត់ដេរ និង តម្បាញ មកពីកម្មវិធី បណ្តុះបណ្តាលវិជ្ជជីវៈ សំរាប់ជនពិការដោយសារគ្រាប់មីន និង ជនប៉ូលីយ្យូ នៅរាជធានីភ្នំពេញបានចូលបំរើការងារជាមួយគ្នា ដើម្បីបង្កើតជា កិច្ច សហ ការ កាត់ដេរ និង តម្បាញ ដោយផលិតនូវសិប្បផលធ្វើពីសូត្រខ្មែរ មាន គុណភាពល្អ និង ផលិតផលធ្វើពី ក្រណាត អំបោះ។




ក្រុមភ្ញៀវទេសចរណ៍ ស្វាគមទទួលរាក់ទាក់ គ្រប់ពេលវេលាពី សមាគម យើងខ្ញុំ។ ចំពោះប្រាក់ចំណោញដែលបានមកពី អស់លោក លោកស្រី ជាវ នៅរោងសិប្បកម្ម យើងខ្ញុំ ក្នុង ខេត្តសៀមរាប និង រាជធានី ភ្នំពេញ នឹង បែងចែកស្មើគ្នាដោយ សិប្បករ សិប្បការិនី រងគ្រោះដោយគ្រាប់មីន និង ជម្ងឺប៉ូលីយ្យូ នៅសមាគមយើងខ្ញុំ ។





<u>សូមមើលគេហទំព័រ</u>: www.cha-cambodia.org

<u>សូមទាក់ទងមកអ៊ីម៉ែលៈ</u> wthanchashop@online.com.kh

<u>សូមទាក់ទងមកលេខទូរស័ព្ទៈ</u>

<u>ភ្នំពេញ</u>:

**855 (0) 12 916 796**
**855 (0) 12 913 861**

<u>លេខហ្វាក់ក៏</u>:

**855 (0) 881 720**

<u>ខេត្ត សៀមរាបៈ</u>

**855 (0) 12 599 154**

<u>អស័យដ្ឋានផ្ញើ</u>◌◌:

ផ្ទះលេខ ៤០ ផ្លូវលេខ ១៦០ សង្កាត់ ទឹកល្អក់ ២
ខណ្ឌ ទួលគោក រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ: ១៣៩៦ រាជធានីភ្នំពេញ

ហាងយើងខ្ញុំបើកបំរើអតិថិជនរៀងរាល់ថ្ងៃ:
ពីម៉ោង ៧◌:៣០ព្រឹក ដល់ ម៉ោង ៥◌:៣០រសៀល

